# ទំនុកដំកើង ១

មនុស្សសុចរិត

១ មានពរហើយ អ្នកណាដែលមិនដើរតាមដំបូន្មាន របស់មនុស្សអាក្រក់
ក៏មិនឈរនៅក្នុងផ្លូវរបស់មនុស្សមានបាប
ឬអង្គុយនៅជាមួយនឹងពួកមនុស្សដែលមើលងាយ
២ អ្នកនោះត្រេកអរតែនឹងក្រឹត្យវិន័យរបស់ព្រះយេហូវ៉ាវិញ
ក៏រំពឹងគិតក្នុងក្រឹត្យវិន័យទ្រង់ទាំងយប់ទាំងថ្ងៃដែរ
៣ អ្នកនោះនឹងដូចជាដើមឈើ ដែលដុះនៅក្បែរផ្លូវទឹក
ដែលបង្កើតផលតាមរដូវកាល
ហើយស្លឹកក៏មិនចេះស្រពោនឡើយ
ឯការអ្វីដែលអ្នកនោះធ្វើ នោះនឹងចំរើនឡើងទាំងអស់

មនុស្សទុចរិត

៤ ចំណែកមនុស្សអាក្រក់ មិនដូច្នោះទេ
គឺគេដូចជាអង្កាមវិញ ដែលខ្យល់ផាត់ខ្ចាត់ខ្ចាយទៅ

៥ ដូច្នេះ ពួកមនុស្សអាក្រក់នឹងមិនធន់នៅក្នុងគ្រាជំនុំជំរះទេ
ឯពួកមានបាប ក៏ឈរក្នុងជំនុំមនុស្សសុចរិតមិនបានដែរ

៦ ដ្បិតព្រះយេហូវ៉ាទ្រង់ជ្រាប ផ្លូវរបស់មនុស្សសុចរិត
តែផ្លូវរបស់មនុស្សអាក្រក់នឹងវិនាសទៅវិញ។